**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥

# សេចក្តីថ្លែងការណ៍រួម
# ដំណើរឆ្ពោះទៅរកវិនាសកម្មព្រៃឡង់

អាត្មាភាព និងយើងខ្ញុំទាំងអស់គ្នាជាព្រះសង្ឃ បណ្តាញសហគមន៍ព្រៃឡង់ សិស្ស និស្សិត បណ្តាញយុវជន បណ្តាញជនជាតិដើមភាគតិច និងព្រៃឈើ និងអង្គការសង្គមស៊ីវិល មានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំងចំពោះស្ថានភាពនៃការកាប់បំផ្លាញព្រៃឡង់យ៉ាងគំហុកនៅប៉ុន្មានឆ្នាំចុងក្រោយ ដែលជាដំណើរមួយឆ្ពោះទៅរកវិនាសកម្មព្រៃឡង់ នៅពេលឆាប់ៗខាងមុខនេះ។

បើទោះបីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ស្តីពី ព្រៃឈើ ច្បាប់ស្តីពីកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងលិខិតបទដ្ឋានសំខាន់ៗមួយចំនួនទៀត ក្នុងគោលបំណងការពារព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថានយ៉ាងណាក៏ដោយ ក៏ប៉ុន្តែសកម្មភាពការកាប់បំផ្លាញព្រៃឈើខុសច្បាប់នៅតែមាន និងការកាប់ឈើក្រោមរូបភាពនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច សម្បទានរ៉ែ សម្បទានសង្គមកិច្ច និងសម្បទានព្រៃគប់។ ដីសម្បទានទាំងនេះបាននិងកំពុងគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ដល់ព្រៃឈើនៅកម្ពុជា ជាពិសេស **ព្រៃឡង់** ដែលជាព្រៃទំនាបចុងក្រោយបង្អស់របស់កម្ពុជា និងនៅឧបទ្វីបឥណ្ឌូចិន។

រយៈពេលជាង១០ឆ្នាំកន្លងមកនេះ ព្រៃឡង់ គឺត្រូវបានកាប់បំផ្លាញ និងឈូសឆាយពីសំណាក់ក្រុមហ៊ុនដីសម្បទាន និងការសិក្សារបស់ក្រុមហ៊ុនរុករករ៉ែ នៅក្នុងតំបន់ព្រៃឡង់។ តំបន់ព្រៃស្រោងរាប់ម៉ឺនហិកតាត្រូវបានកាប់បំផ្លាញ និងដាំជំនួសដោយដើមកៅស៊ូ ដំឡូងមី និងការធ្វើអាជីវកម្មរ៉ែដែក និងវត្ថុធាតុដើមផ្សេងៗទៀត។ យោងតាមរបាយការណ៍ស្រាវជ្រាវថ្នាក់ឃុំ បែបបរិមាណរបស់បណ្តាញសហគមន៍ព្រៃឡង់ ដែលចេញផ្សាយកាលពីខែមេសា ឆ្នាំ២០១៥ នេះបានបង្ហាញថា នៅក្នុងឃុំចំនួន៣៣ ក្នុងតំបន់ព្រៃឡង់ និងឃុំផ្សេងទៀតដែលជាប់ព្រំប្រទល់ឃុំទាំង៣៣នេះ មានក្រុមហ៊ុនសម្បទានសរុបចំនួន៥៣ក្រុមហ៊ុន ដែលបានប្រតិបត្តិការ និងកំពុងតែប្រតិបត្តិការ គិតត្រឹមចុងឆ្នាំ២០១៣។ ទំហំដីសម្បទានទាំងអស់គឺ ១សម្បទានដីសេដ្ឋកិច្ច២៣៤,៧៨៤.០៨ ហិកតា សម្បទានរ៉ែ ២៦៤,៦៩៣.២៣ ហិកតា សម្បទានព្រៃឈើ៨៨៤.២០ ហិកតា និងសម្បទានដីសង្គមកិច្ចចំនួន ៤000.00 ហិកតា។

នាពេលបច្ចុប្បន្ននេះក្រៅពីគម្រោងដីសម្បទាន យើងខ្ញុំរកឃើញថា ការកាប់ព្រៃឈើធ្វើអាជីវកម្ម និងការកាប់រានដីព្រៃធ្វើកម្មសិទ្ធិឯកជនកំពុងតែមានការកើនឡើងយ៉ាងខ្លាំងក្លា ដែលក្នុងនោះសហគមន៍បានអះអាងថាមានការជាប់ពាក់ព័ន្ធជាមួយមន្ត្រីរាជរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានមួយចំនួន។ រហូតមកដល់ពេលនេះ ឈើជាច្រើនម៉ឺនម៉ែត្រគូបត្រូវបានដឹកចេញពីតំបន់ព្រៃឡង់ ដើមជ័រច្បោះសហគមន៍រាប់សិបម៉ឺនដើមត្រូវបានកាប់បំផ្លាញ ផ្ទៃដីព្រៃរាប់ម៉ឺនហិកតាត្រូវបានកាប់រានក្លាយជាទីវាលយ៉ាងអនាធិបតេយ្យ ដោយគ្មានការទប់ស្កាត់ពីមន្ត្រីជំនាញ និងអាជ្ញាធរពាក់ព័ន្ធបើមានក៏តិចតួចបំផុត។ ចំណែកសហគមន៍ដោយមើលឃើញគ្រោះមហន្តរាយព្រៃឡង់ដូច្នេះ

បាននិងកំពុងខិតខំការពារ ទប់ស្កាត់បទល្មើសព្រៃឈើនិងការរុករានខុសច្បាប់ តែត្រូវបានទទួលរងនូវការគម្រាមសម្លាប់ និងការគម្រាមកំហែងនានាពីសំណាក់អ្នកប្រព្រឹត្តបទល្មើស មន្រ្តីជំនាញ និងអាជ្ញាធរដែនដីមួយចំនួនទៅវិញ។

ជាច្រើនឆ្នាំមកហើយ បណ្តាញសហគមន៍ព្រៃឡង់ យុវជន និងបណ្តាញអង្គការសង្គមស៊ីវិលបានដាក់ញត្តិ ពាក្យបណ្តឹង និងស្នើសុំអន្តរាគមន៍ទៅរាជរដ្ឋាភិបាល និងស្ថាប័នជំនាញ ដើម្បីបង្កើតយន្តការផ្នែកច្បាប់ការពារព្រៃឡង់ ការសហការ និងធ្វើការរួមគ្នាដើម្បីការពារនិងសហគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ជាក់ស្តែងកាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥ នេះ តំណាងសហគមន៍ព្រៃឡង់ចំនួន៣៤ នាក់ បានដាក់ញត្តិស្នើសុំអន្តរាគមន៍ពីរដ្ឋសភា ស្ថាប័នរដ្ឋាភិបាល និងគណបក្សនយោបាយធំៗទាំងពីរដែលមានអាសនៈនៅក្នុងសភាជាតិ ប៉ុន្តែរហូតដល់ពេលនេះនៅមិនទាន់ទទួលបាននូវការឆ្លើយតបណាមួយនៅឡើយ។

អាត្មាភាព និងយើងខ្ញុំទាំងអស់គ្នាជាព្រះសង្ឃ បណ្តាញសហគមន៍ព្រៃឡង់ សិស្ស និស្សិត បណ្តាញយុវជន បណ្តាញសហគមន៍ព្រៃឈើ បណ្តាញជនជាតិដើមភាគតិច និងព្រៃឈើ និងអង្គការសង្គមស៊ីវិល មានការព្រួយបារម្ភយ៉ាងខ្លាំងលើការបាត់បង់ព្រៃឈើ ដីព្រៃឈើ ជីវចម្រុះ និងធនធានជលផលក្នុងរយៈពេលយ៉ាងខ្លីខាងមុខនេះ បើសិនមិនមានអន្តរាគមន៍ដោះស្រាយទាន់ពេលវេលាទេ នឹងធ្វើឲ្យប៉ះពាល់កម្មវិធីស្តារគម្របព្រៃឈើ កម្មវិធីឥណទានកាបូន ជាពិសេសប៉ះពាល់ដល់ការជួយរក្សាលំនឹងទឹក និងផ្គត់ផ្គង់ទឹកទៅឱ្យទន្លេសាបដែលបណ្តាលឲ្យមានអតុល្យភាពលំនឹងទឹកក្រោមដីផងដែរ។ ចុះប្រសិនបើព្រៃឡង់បាត់បង់ តើនឹងមានអ្វីកើតឡើងចំពោះទន្លេសាបដែលជាបេះដូងរបស់ប្រទេសកម្ពុជា បន្ថែមពីលើនេះទៀតនឹងធ្វើឲ្យប៉ះពាល់ ឬបាត់បង់ដល់ជម្រកសត្វព្រៃ ជម្រកត្រីពង និងមុខរបររបស់ប្រជាសហគមន៍រាប់ម៉ឺនគ្រួសារដែលពឹងផ្អែកលើការរកផលអនុផលព្រៃឈើ ផលនេសាទ ជាពិសេសបាត់បង់នូវប្រភពផ្គត់ផ្គង់ទឹកសម្រាប់វិស័យកសិកម្ម និងប្រើប្រាស់ប្រចាំថ្ងៃ សម្រាប់ប្រជាពលរដ្ឋនៅជុំវិញតំបន់នោះ មិនតែប៉ុណ្ណោះការបាត់បង់ព្រៃឡង់មានឥទ្ធិពលដល់ប្រជានេសាទចំនួន ១លាន ប្រាំសែននាក់ដែលកំពុងទទួលផលដោយផ្ទាល់ពីទន្លេសាប[1]។

អាត្មាភាព និងយើងខ្ញុំទាំងអស់គ្នា មិនប្រឆាំងចំពោះការអភិវឌ្ឍន៏នោះទេ តែសូមអោយអនុវត្តទៅតាមនីតិវិធីច្បាប់ឲ្យបានត្រឹមត្រូវ ធានាបាននូវសមធម៌នៃគម្រោងអភិវឌ្ឍន៍ និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គមអោយបានក្នុងកំរិតអប្បបរមា។

យោងតាមសេចក្តីដូចបានជម្រាបជូនខាងលើអាត្មាភាព យើងខ្ញុំទាំងអស់គ្នា សូមបិណ្ឌបាត្រ និងសំណូមពរដល់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រដ្ឋបាលព្រៃឈើ តុលាការ និងស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ នូវសំណើមួយចំនួនដូចខាងក្រោម៖

**១.** ចាត់វិធានការ និងអន្តរាគមន៍ជាបន្ទាន់ដើម្បីទប់ស្កាត់បទល្មើសព្រៃឈើក្នុងតំបន់ព្រៃឡង់។

**២.** អន្តរាគមន៍ឲ្យមានការបង្ហាញសេចក្តីព្រាងអនុក្រឹត្យស្តីពីតំបន់ព្រៃការពារ និងអភិរក្សជីវចម្រុះព្រៃឡង់ និងបើកចំហការពិគ្រោះយោបល់ជាសាធារណៈជាមួយសហគមន៍ព្រៃឡង់ និងអ្នកពាក់ព័ន្ធ។

[1] New York Time, June 9th, 2014, “Of fish Monsoons, and the Future”.

៣.ដាក់បញ្ចូលបណ្តាញសហគមន៍ព្រៃឡង់ទាំងបួនខេត្ត ជាតំបន់សហគ្រប់គ្រងព្រៃឡង់ ដោយផ្តល់ភាពស្របច្បាប់ តាមរយៈការដាក់បញ្ចូលសិទ្ធិ និងតួនាទីរបស់បណ្តាញសហគមន៍ព្រៃឡង់ ក្នុងអនុក្រឹត្យស្តីពីតំបន់ព្រៃការពារ និងអភិរក្សជីវចម្រុះព្រៃឡង់។

៤.អន្តរាគមន៍ទៅមន្ត្រីរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ ដើម្បីចុះស៊ើបអង្កេតនៅតំបន់ព្រៃឡង់ និងជំរុញឲ្យមានប្រសិទ្ធភាពចំពោះការអនុវត្តច្បាប់ពាក់ព័ន្ធនិងវិស័យព្រៃឈើ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការផ្តល់សម្បទានដីសង្គមកិច្ច និងការទន្ទ្រានដីពីជនចំណាកស្រុកខុសច្បាប់។

៥.ចាត់វិធានការតាមផ្លូវច្បាប់ដល់មន្ត្រី និងអាជ្ញាធរដែនដីទាំងឡាយដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្មឈើ និងការកាប់បំផ្លាញឈើក្នុងតំបន់ព្រៃឡង់ដោយខុសច្បាប់។

៦.សូមឲ្យបញ្ឈប់គ្រប់រូបភាពគម្រាមកំហែង ពីប្រព័ន្ធតុលាការ និងកងកម្លាំងមានសមត្ថកិច្ចចំពោះសកម្មជនព្រៃឡង់។

៧.សូមរក្សាទុកតំបន់ព្រៃឡង់ ជាតំបន់សិក្សាស្រាវជ្រាវអប់រំសម្រាប់បណ្តុះបណ្តាលធនធានមនុស្ស ក្នុងការលើកស្ទួយវិស័យអប់រំផ្នែកបរិស្ថាន ធនធានធម្មជាតិ និងអេកូទេសចរណ៍។

៨.ពិនិត្យមើលឡើងវិញនូវការប្រើប្រាស់រណាយន្ត អោយបានសមស្របទៅតាមនិតិវិធីច្បាប់ដូចចែងក្នុងច្បាប់ព្រៃឈើជំពូកទី១៣ ស្តីពីវិធានការគ្រប់គ្រងសកម្មភាពព្រៃឈើ មាត្រា៧០ ។ ប្រសិនបើការគ្រប់គ្រងមិនមានប្រសិទ្ធភាព សូមផ្អាកឬបញ្ឈប់អោយមានការនាំចូលរណាយន្តមកក្នុងប្រទេសកម្ពុជា។

៩. សូមបែងចែកកញ្ចប់ថវិកាជាតិដើម្បីកិច្ចការពារព្រៃឡង់។

១០. សូមដាក់បញ្ចូលតំបន់ព្រៃឡង់ទៅក្នុងកម្មវិធីវេជបូកថ្នាក់ជាតិ។


**<u>ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖</u>**

| | | |
|---|---|---|
| ១. លោក តឹក វណ្ណារ៉ា | នាយកប្រតិបត្តិវេទិកានៃអង្គការមិនរដ្ឋាភិបាលស្តីពីកម្ពុជា | ០១២ ៧៩៣ ៤៨៩ |
| ២. លោក សេង សុខហេង | អ្នកសម្របសម្រួលលេខាធិការដ្ឋាន CDPS-CPN | ០៩២ ៣២៤ ៦៦៨ |
| ៣. លោក ទឹម ម៉ាឡៃ | ប្រធានបណ្តាញយុវជនកម្ពុជា | ០១៧ ៩៩០ ៦៨៩ |
| ៤. លោក សៅ វណ្ណសី | នាយកប្រតិបត្តិអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច | ០១២ ៨១៣ ៧៤៤ |
| ៥. លោក យស ភារី | ប្រធានអង្គការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ | ០១២ ៦០០ ៨៣០ |
| ៦. លោកស្រី មុំ សាគីន | សមាជិកបណ្តាញកសាងសន្តិភាពសហគមន៍ | ០៨៩ ៩៤២ ១៥៩ |
| ៧. លោក ហឿន សុភាព | សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តកំពង់ធំ | ០១២ ៣៧៣ ៤៤១ |
| ៨. លោក រស់ ឡាច | សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តស្ទឹងត្រែង | ០៩៧ ៥៥៨ ៥៩០៦ |
| ៩. លោក ផៃ ប៊ុនលាង | សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តក្រចេះ | ០៩៧ ៨០២៨ ៤១១ |
| ១០. លោកស្រី ភោគ ហុង | សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តព្រះវិហារ | ០១២ ៩៤៨ ៦៨២ |

**<u>បណ្ដាញ និងអង្គការសង្គមស៊ីវិល ដែលគាំទ្រលើសេចក្ដីថ្លែងការណ៍៖</u>**

១. បណ្ដាញសហគមន៍ព្រៃឡង់ (PLCN)
២. បណ្ដាញកសាងសន្តិភាពសហគមន៍ (CPN)
៣. វេទិកាអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា (NGOF)
៤. អង្គការអភិវឌ្ឍន៍សហគមន៍ដើម្បីសន្តិភាព និងនិរន្តរភាព (CDPS)
៥. បណ្ដាញយុវជនកម្ពុជា (CYN)
៦. អង្គការពន្លកខ្មែរ (PKH)
៧. អង្គការជីវិតថ្លៃថ្នូរ (LWD)
៨. អង្គការអុកស្វាម (OXFAM in Cambodia)
៩. អង្គការដេនមីសស៊ិន (DANMISSION)
១០. អង្គការស្ពានសន្តិភាព (PBO)
១១. អង្គការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ (CED)
១២. អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (ICSO)
១៣. អង្គការអប់រំសុខភាព និងបរិស្ថាន(EHEO)
១៤. អង្គការលើកកម្ពស់វប្បធម៌ជនជាតិដើមភាគតិចកួយ (OPKC)
១៥. អង្គការអភិវឌ្ឍន៍សម្លេងសហគមន៍ (BCV)
១៦. អង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ (AFD)
១៧. អង្គការផេកកម្ពុជា (PACT)
១៨. គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមន៍ការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
១៩. អង្គការសកម្មភាពដើម្បីសុខុមាលភាពស្ត្រីកម្ពុជា (KWWA)
២០ .សមាគមន៍យុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA)
២១. ក្រុមការងារសិទ្ធិលំនៅឋាន (HRTF)
២២. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
២៣.សម្ពន្ធ័អង្គការមិនមែនរដ្ឋាភិបាលស្ដីពីបរិស្ថាន និងការប្រែប្រួលអាកាសធាតុ(NECA)
២៤.សមាគមអភិវឌ្ឍន៍ជនបទ (RDA)
២៥. សមាគមចំរើនជាតិ (NAPA)
២៦.អង្គការវីជីឡែន (Vigilance)
២៧. អង្គការអនុផលព្រៃឈើ(NTFP)
២៨ អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA)
២៩.ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (CRDT)
៣០.មជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ (MPC)
៣១.អង្គការកសិករខ្មែរសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍កសិកម្ម (KFCADO)
៣២.អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន (EPDO)
៣៣.សមាគមន៍ខ្មែរលើ- រតនគិរី (HA)
៣៤. បណ្ដាញសមាជិកសកម្មសិទ្ធិជនជាតិដើមភាគតិច (IRAM)
៣៥. អង្គការម្លប់បៃតង (Mlup Baitong)

៣៦. ក្រុមអភិវឌ្ឍន៍ភូមិ (KAWP)
៣៧. អង្គការព្រះពុទ្ធសាសនាដើម្បីសន្តិភាព (BPO)
៣៨. អ្នកអភិវឌ្ឍន៍សហគមន៍ (NAS)
៣៩. អង្គការអភិវឌ្ឍន៍ស្ត្រី (AS)
៤០. អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទពល្សសាន្ត (NRD)
៤១. អង្គការសហព័ន្ធអភិវឌ្ឍន៍កសិកម្មចម្រុះកម្ពុជា (FIDAC)
៤២. សមាគមអភិវឌ្ឍបង្កើនសេដ្ឋកិច្ចគ្រួសារ (ADIFE)
៤៣. អង្គការជំនួយជនបទ (RAO)
៤៤. អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង (UPWD)
៤៥. អង្គការគោលដៅយើង (OOO)
៤៦. សមាគមអភិវឌ្ឍន៍ធនធានសេដ្ឋកិច្ច (DARE)
៤៧. អង្គការជនជាតិដើមភាគតិចកម្ពុជា( CIPO)
៤៨. សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)
៤៩. សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA)